ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ញត្តិថ្កោលទោស

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងការសោកស្តាយយ៉ាងខ្លាំងបំផុត និងថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើទុយ៌ស អសីលធម៌ ថោកទាប និងគ្មានតម្លៃជាមនុស្សរបស់ជនជាតិថៃមួយចំនួន បានវាយប្រហារមកលើ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា** ដែលជារដ្ឋបុរសប្រកបដោយក្រមសីលធម៌ គុណធម៌ និងស្មារតីទទួលខុសត្រូវខ្ពស់សម្រាប់មនុស្សជាតិ និងឥស្សរជនកម្ពុជាមួយចំនួនទៀត នាពេលថ្មីៗនេះ។

ក្នុងខណៈពេលដែលកម្ពុជាកំពុងអនុវត្តបទឈប់បាញ់ជាមួយថៃ និងប្រកាន់ជំហរដោះស្រាយបញ្ហាព្រំដែនប្រកបដោយភាពចាស់ទុំខាងនយោបាយការទូតយ៉ាងម៉ឺងម៉ាត់ និងការកសាងព្រំដែនសន្តិភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសជិតខាង មានជនជាតិថៃមួយចំនួនបានបង្កអរិភាពជាមួយកម្ពុជាដោយបានធ្វើសកម្មភាពអសីលធម៌ ប្រមាថមាក់ងាយដល់វីរបុរសកម្ពុជា និងឥស្សរជនកម្ពុជា ក្នុងន័យញុះញង់ឱ្យកងទ័ព និងប្រជាជនកម្ពុជាទាំងមូលឱ្យអស់ការអត់ធ្មត់ និងបំពានបទឈប់បាញ់ ដើម្បីមួលបង្កាច់បង្ខូចកម្ពុជាថាជាដើមហេតុបង្កជម្លោះ ផ្ទុះសង្គ្រាមបំពានបទឈប់បាញ់មុន ដូចដែលប្រទេសថៃកំពុងធ្វើបង្ហាញដល់អន្តរជាតិបានឃើញ។ អាកប្បកិរិយាបែបនេះ គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ គុណតម្លៃនៃស្មារតីមិត្តភាព ការគោរពគ្នាទៅវិញទៅមក និងសន្តិសហវិជ្ជមានរវាងប្រទេសទាំងពីរក្នុងនាមជាអ្នកជិតខាងល្អ ជាសមាជិកអាស៊ាន និងសហគមន៍អន្តរជាតិ។

ទន្ទឹមនេះ យើងខ្ញុំសូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះប្រសាសន៍ **សម្តេចតេជោ** ដែលបានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែររក្សាភាពស្ងៀមស្ងាត់ ឆ្លើយតបដោយភាពថ្លៃថ្នូរ ឯកភាពជាតិ អត់ធ្មត់ខ្ពស់ និងបន្តលើកកម្ពស់ការពង្រឹងអធិបតេយ្យភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិ ដោយប្រើប្រាស់រូបិយវត្ថុជាតិ និងត្រូវបន្តប្រកាន់ខ្ជាប់ជាជាតិសាសន៍ថ្លៃថ្នូរ និងមានសីលធម៌ខ្ពស់ជានិច្ច បើទោះបី **សម្តេចតេជោ** ទទួលរងនូវការប្រមាថដោយចេតនា និងគ្មានសីលធម៌បែបនេះក្តី។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើអសីលធម៌ អាកប្បកិរិយាដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កិត្តិយសរបស់ឥស្សរជនកម្ពុជា។

ថ្ងៃពុធ ១រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥